ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ
## ស្តីពី
# ការគ្រប់គ្រងសពអ្នកជំងឺទូទៅ
# នៅតាមមន្ទីរពេទ្យ និងផ្ទះ ប្រកបដោយសុវត្ថិភាព

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ៤៦១ សស.ឧស

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសពអ្នកជំងឺទូទៅនៅតាមមន្ទីរពេទ្យ និងផ្ទះ ប្រកបដោយសុវត្ថិភាព

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឲ្យអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសពអ្នកជំងឺទូទៅនៅតាមមន្ទីរពេទ្យ និងផ្ទះប្រកបដោយសុវត្ថិភាព ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**ប្រការ៣ .-**

ខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

**ម៉ម ប៊ុនហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

## ១. សេចក្តីផ្តើម

ក្រសួងសុខាភិបាលបានចេញសេចក្តីសម្រេចលេខ០៧៨ ស.នក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ស្តីពីដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការចាត់ចែងសពដែលមានផ្ទុកមេរោគកូវីដ-១៩ រួចហើយ។ យោងកិច្ចប្រជុំគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ និងឈរលើមូលដ្ឋាននៃការគ្របដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីបង្កើតឱ្យមានប្រព័ន្ធភាពស៊ាំនៅក្នុងសហគមន៍ ដែលរហូតមកដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ បានរហូតដល់ ៨៥.២២% នៃចំនួនប្រជាជនសរុប ១៦លាននាក់ សពដែលមិនមែនជាអ្នកជំងឺកូវីដ-១៩ ហើយស្លាប់ដោយសារជំងឺ ឬមូលហេតុផ្សេងៗ នៅតាមមន្ទីរពេទ្យ ឬផ្ទះ មិនតម្រូវឱ្យធ្វើតេស្តរកមេរោគកូវីដ-១៩ ទៀតទេ។ ដូច្នេះ ដើម្បីបង្ការ និងទប់ស្កាត់ការចម្លងរោគផ្សេងៗជាយថាហេតុ ការគ្រប់គ្រង និងចាត់ចែងសពត្រូវអនុវត្តតាមវិធានការណ៍សុខាភិបាល និងស្របតាមទំនៀមទំលាប់ប្រពៃណីសាសនាក្នុងបរិបទកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក្រសួងសុខាភិបាលបានរៀបចំគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសពអ្នកជំងឺទូទៅ នៅតាមមន្ទីរពេទ្យ និងផ្ទះ ប្រកបដោយសុវត្ថិភាព។

## ២. គោលការណ៍គ្រឹះនៃការគ្រប់គ្រងសព

ការគ្រប់គ្រងសព ត្រូវឈរលើគោលការណ៍គ្រឹះ ៣យ៉ាង ដើម្បីការពារសេចក្តីថ្លៃថ្នូររបស់សព និងរក្សាតុល្យភាពរវាងសិទ្ធិរបស់គ្រួសារសពនិងភាពចាំបាច់ក្នុងបង្ការហានិភ័យនៃសុខភាពសាធារណៈ។

**គោលការណ៍គ្រឹះ នៃការគ្រប់គ្រងសពអ្នកជំងឺទូទៅ**

| ១. សុវត្ថិភាពនៃការរៀបចំទុកដាក់សព | ២. គោរពសេចក្តីថ្លៃថ្នូររបស់សព | ៣. បន្ថយហានិភ័យសុខភាពសាធារណៈ |
| --- | --- | --- |
| អនុវត្តវិធានការបង្ការការឆ្លងរោគតាមនិយាមស្តង់ដារ ដោយមានសម្ភារៈលាងសម្អាតដៃឬទឹកសម្លាប់មេរោគ និងពាក់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ។ | រៀបចំទុកដាក់សពឱ្យបានសមរម្យ តាមទំនៀមទម្លាប់ប្រពៃណី និងសាសនា ដោយ ផ្អែកតាមកម្រិតហានិភ័យនៃការចម្លងជំងឺ និង **វិធានការសុខាភិបាលជាធរមាន** ។ | សម្អាតបរិស្ថាន និងរក្សាអនាម័យល្អ ដើម្បីបង្ការការចម្លងរោគនៅគេហដ្ឋាន កន្លែងរក្សាសព ទីបូជាសព ឬបញ្ចុះសព និងទីតាំងជុំវិញ។ |

## ៣. ក្រុមប្រជាជនជាគោលដៅ

គោលការណ៍ណែនាំនេះ គឺជាឧបករណ៍បច្ចេកទេសជាសារវន្តសម្រាប់បុគ្គលិកពេទ្យ និងគ្រួសារសព អាចារ្យវត្ត ព្រះសង្ឃ ឬអ្នកកាន់សាសនាផ្សេងទៀត ក្រុមអ្នកបូជាសព ឬអ្នកបញ្ចុះសព ប្រជាជនទាំងអស់ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ប្រើប្រាស់ក្នុងការគ្រប់គ្រង រៀបចំចាត់ចែងសពអ្នកជំងឺទូទៅនៅតាមមន្ទីរពេទ្យ និងផ្ទះ ប្រកបដោយសុវត្ថិភាព។

## ៤. ឧបករណ៍ការពារខ្លួន និងសម្ភារៈចាំបាច់ក្នុងការគ្រប់គ្រងសពអ្នកជំងឺទូទៅ

តារាងខាងក្រោមរៀបរាប់អំពីឧបករណ៍ការពារផ្ទាល់ខ្លួន និងសម្ភារៈចាំបាច់នានា សម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងសពអ្នកជំងឺទូទៅ ដើម្បីរក្សាសុវត្ថិភាពបុគ្គល រក្សាបរិស្ថាន និងអនាម័យល្អ នៅក្នុងមន្ទីរពេទ្យ គេហដ្ឋាន វត្តអារាម ឬទីតាំងវិហារសាសនាផ្សេងទៀត យានយន្តដឹកជញ្ជូនសព និងទីតាំងបូជាសពឬបញ្ចុះសព។ សូមពិនិត្យមើលបន្ថែមអំពីប្រភេទឧបករណ៍ និងសម្ភារៈដែលត្រូវប្រើប្រាស់ ទៅតាមសកម្មភាពជាក់លាក់នីមួយៗនៃការគ្រប់គ្រងសព។ អ្នកពាក់ព័ន្ធនឹងការគ្រប់គ្រងសពអាចប្រើប្រាស់តារាងនេះជា **«បញ្ជីផ្ទៀងផ្ទាត់»** ដើម្បីបញ្ជាក់ថាឧបករណ៍ការពារខ្លួន និងសម្ភារៈចាំបាច់នានា ត្រូវបានត្រៀមបម្រុងរួចជាស្រេច សម្រាប់ការប្រើប្រាស់នៅមុន និងក្រោយពេលអនុវត្តសកម្មភាពនីមួយៗ ។

| ឧបករណ៍ការពារខ្លួននិងសម្ភារៈចាំបាច់ក្នុងការគ្រប់គ្រងចាត់ចែងសពអ្នកជំងឺទូទៅ | | ផ្ទៀងផ្ទាត់ |
|---|---|---|
| **ការលាងសម្អាតដៃ មុន និងក្រោយពេលលើកទុកដាក់សព** | 1. ទឹកអាល់កុលសម្រាប់លាងសម្អាតដៃ<br>2. ទឹកស្អាត<br>3. សាប៊ូ<br>4. ក្រដាសជូតដៃប្រើហើយបោះចោល | ✓<br>✓<br>✓<br>✓ |
| **សម្ភារៈនិងឧបករណ៍ការពារខ្លួន នៅពេលរៀបចំសព** | 1. ម៉ាសពេទ្យ<br>2. ស្រោមដៃ (ប្រើម្តងបោះចោល ឬ ស្រោមដៃធ្វើការធ្ងន់ៗ)<br>3. ស្រោមដៃជ័រ<br>4. ក្នុងករណីអាចប៉ះពាល់សារធាតុរាវចេញពីខ្លួនសព អ្នកប៉ះពាល់ផ្ទាល់ជាមួយសពត្រូវប្រើប្រាស់បន្ថែមៈ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់មិនជ្រាបទឹក | ✓<br>✓<br>✓<br>✓ |
| **ការគ្រប់គ្រងសំណល់ និងការសម្អាតបរិស្ថាន** | 1. ថង់ផ្លាស្ទិក សម្រាប់ដាក់សព (ប្រើតែក្នុងករណីអាចមានតំណក់ទឹកចេញពីផ្លូវដង្ហើម ឬវត្ថុរាវចេញពីខ្លួនសពប៉ុណ្ណោះ)<br>2. ថង់ដាក់សំណល់ឆ្លងរោគ (ប្រើម្តងហើយបោះចោល)<br>3. សាប៊ូ និងទឹក ឬសាប៊ូបោកសម្លៀកបំពាក់<br>4. សារធាតុរាវសម្រាប់សម្លាប់មេរោគលើផ្ទៃរឹងៈ សូលុយស្យុងអ៊ីប៉ូក្លរីត 0,១% (១000 ppm) ឬ អេតាណុលកម្រិត ៧0% ឬសារធាតុសម្លាប់មេរោគ។ | ✓<br>✓<br>✓<br>✓ |

## ៥. ការគ្រប់គ្រងសពអ្នកជំងឺទូទៅ

ការគ្រប់គ្រងសព គឺជាវំហូរសកម្មភាពនៃការរៀបចំចាត់ចែងសពអ្នកជំងឺដែលបានស្លាប់ ដោយចាប់ផ្តើមពីការរៀបចំសពនៅក្នុងបន្ទប់អ្នកជំងឺនៅមន្ទីរពេទ្យ ការចាត់ចែងដឹកជញ្ជូនសពចេញពីមន្ទីរពេទ្យ រហូតដល់ការរៀបចំពិធីបូជាសពឬបញ្ចុះសព។ សកម្មភាពទាំងអស់ប្រព្រឹត្តឡើងនៅតាមទីតាំងផ្សេងៗគ្នា ហើយទាក់ទងនឹងអ្នកអនុវត្តច្រើនផ្នែក។

ការគ្រប់គ្រងសពអ្នកជំងឺទូទៅទាក់ទងនឹងសកម្មភាពសំខាន់ៗមួយចំនួន ដូចជា៖

1. ការរៀបចំសពនៅមន្ទីរពេទ្យ
2. ការរៀបចំសព ការតំកល់សព និងពិធីបុណ្យសពនៅគេហដ្ឋាន
3. ការដឹកជញ្ជូនសព និងការដង្ហែសព
4. ការបូជាសពឬបញ្ចុះសព
5. ការគ្រប់គ្រង និងសម្អាតបរិស្ថាន នៅមន្ទីរពេទ្យ គេហដ្ឋាន ទីតាំងបូជាឬបញ្ចុះសព

សកម្មភាពនៃការរៀបចំនិងគ្រប់គ្រងសព ត្រូវអនុវត្តដោយអ្នកពាក់ព័ន្ធផ្ទាល់ ដូចជាក្រុមគ្រួសារសព ក្រុមអ្នកដឹកជញ្ជូនសព និងក្រុមអ្នកបូជាសពឬបញ្ចុះសព ។ល។ ដូច្នេះ ការគ្រប់គ្រងសព ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវវិធានការការពារខ្លួន ដោយប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួន និងសម្ភារៈចាំបាច់ផ្សេងទៀតឱ្យបានត្រឹមត្រូវទៅតាមកាលៈទេសៈនីមួយៗ ឧ.ទា. ពេលរៀបចំសព និងតំកល់សព នៅក្នុងគេហដ្ឋាន វត្តអារាម ឬទីតាំងវិហារសាសនាផ្សេងទៀត ពេលដឹកជញ្ជូនសពចេញ ពេលបូជាសពឬបញ្ចុះសព ជាដើម។

## ៥.១. ការរៀបចំសពនៅមន្ទីរពេទ្យ (មិនមែនជាមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩)

ការគ្រប់គ្រងសពអ្នកជំងឺដែលស្លាប់នៅក្នុងមន្ទីរពេទ្យ ជាសមត្ថកិច្ចរបស់មន្ទីរពេទ្យ។ ការរៀបចំសពបន្ទាប់ពីស្លាប់ភ្លាម និងការរក្សាតំកល់សពមុនពេលបញ្ជូនចេញពីមន្ទីរពេទ្យ គឺជាភារកិច្ចរបស់មន្ទីរពេទ្យ។ ក្នុងករណីពុំមានក្រុមគ្រួសារសពមកទទួលយកទេ មន្ទីរពេទ្យអាចប្រគល់សាកសពជូន អាជ្ញាធរមានសមត្ថកិច្ច ឬវត្តអារាម ឬសមាគមសាសនា ដើម្បីរៀបចំពិធីបុណ្យសព និងចាត់ចែងបូជាឬបញ្ចុះសព ឱ្យបានសមរម្យតាមទំនៀមទំលាប់ប្រពៃណី សាសនា។

សពដែលត្រូវបានសម្អាត និងរុំ/វេចខ្ចប់ត្រឹមត្រូវរួចរាល់ហើយ ត្រូវប្រគល់ ឬដឹកជញ្ជូនសពជូនក្រុមគ្រួសារ ឬញាតិមិត្ត យកទៅរៀបចំពិធីបុណ្យសព ។ **គ្រូពេទ្យ បុគ្គលិក ដែលមានភារកិច្ចរៀបចំសព** ត្រូវអនុវត្តតាមវិធានការខាងក្រោម៖

| វិធានការត្រូវអនុវត្ត | | |
|---|---|---|
| 1. | លាងដៃឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូ មុន និងក្រោយពេលប៉ះពាល់សព ព្រមទាំងសម្អាតបរិស្ថាននៅជុំវិញទីនោះឱ្យបានស្អាតល្អ។ | ✓ |
| 2. | ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាស់ពេទ្យធម្មតា អាវពេទ្យ និងស្រោមដៃ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវអៀមមិនជ្រាបទឹកបន្ថែមទៀត។ | ✓ |
| 3. | កាត់បន្ថយការធ្វើចលនាសពឱ្យនៅតិចបំផុត ដោយចៀសវាង លើកទុកដាក់សពដែលមិនចាំបាច់ ដើម្បីបង្ការការចេញខ្យល់ ឬទឹកពីក្នុងសួត ឬពីសព។ | ✓ |
| 4. | ដោះសម្ភារៈ បរិក្ខារពេទ្យ ដែលនៅជាប់នឹងខ្លួនសពឱ្យអស់ ដូចជាខ្សែ សេរ៉ូម ម្ជុល ឬបំពង់ផ្សេងៗ នៅមុនពេលរៀបចំរុំសព។ | ✓ |
| 5. | ប្រើប្រាស់សំឡីញាត់ចូលក្នុងរន្ធច្រមុះ មាត់ រន្ធត្រចៀក រន្ធគូទ រន្ធផ្លូវភេទរបស់សពឱ្យបានត្រឹមត្រូវ ដើម្បីបង្ការទឹកហូរចេញក្រៅ។ | ✓ |
| 6. | មិនចាំបាច់សម្លាប់មេរោគលើសព ឬចាក់សារធាតុរាវផ្សេងៗ ចូលទៅក្នុងសារពាង្គ | ✓ |
| 7. | រុំសពដោយក្រណាត់ដោយមិនចាំបាច់ប្រើថង់ផ្លាស្ទិកឬអាចប្រើថង់ផ្លាស្ទិក ក្នុងករណីមានទឹកច្រើនហូរចេញពីសព។ | ✓ |

## ៥.២. ការរៀបចំសព ការតំកល់សព និងពិធីបុណ្យសពនៅគេហដ្ឋាន

ការគ្រប់គ្រងសពដែលស្លាប់នៅតាមផ្ទះ ជាបន្ទុករបស់ក្រុមគ្រួសារសព។ ក្នុងការរៀបចំសពបន្ទាប់ពីស្លាប់ភ្លាម និងការរក្សាតំកល់សព ក្រុមគ្រួសារសពអាចស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន ឬបុគ្គលិកសុខាភិបាល។ ក្នុងការរៀបចំពិធីបុណ្យសព និងចាត់ចែងបូជា ឬបញ្ចុះសព ក្រុមគ្រួសារសពត្រូវទទួលខុសត្រូវរៀបចំផ្ទាល់ ឬអាចស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋាន វត្តអារាម ឬសមាគមសាសនា ដើម្បីរៀបចំ ឱ្យបានសមរម្យតាមទំនៀមទំលាប់ប្រពៃណី សាសនា។

ក្រុមគ្រួសារ ញាតិមិត្ត ឬអ្នកពាក់ព័ន្ធ ត្រូវអនុវត្តនូវវិធានការសុខាភិបាលដើម្បីបង្ការ និងទប់ស្កាត់ការចម្លងរោគជាយថាហេតុ នៅក្នុងគេហដ្ឋាន និងសហគមន៍ ដូចខាងក្រោម៖

1. អ្នកមានភារៈកិច្ចរៀបចំទុកដាក់សព ត្រូវប្រើឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ហើយសម្ភារៈទាំងនោះត្រូវប្រើតែម្តងគត់ និងត្រូវបោះចោលឱ្យបានត្រឹមត្រូវ តាមការណែនាំ។ នៅមុនពេលរៀបចំចាត់ចែងសព ត្រូវត្រៀមឧបករណ៍ការពារខ្លួនដូចរៀបរាប់ក្នុងតារាងឧបករណ៍ការពារខ្លួននិងសម្ភារៈចាំបាច់ក្នុងការគ្រប់គ្រងចាត់ចែងសពអ្នកជំងឺទូទៅ ឱ្យបានរួចរាល់។
2. ការរៀបចំសម្អាត ការរុំវេចខ្ចប់សព និងការដាក់ក្នុងមឈូសត្រូវធ្វើឱ្យបានលឿនបំផុត។ ក្តារមឈូសត្រូវបិទឱ្យបានជិតមាំល្អ និងធានាថា គ្មានការលេចធ្លាយនូវសារធាតុរាវដែលហូរចេញពីសាកសពចេញមកខាងក្រៅឡើយ។ ហាមបើកក្តារមឈូស ដើម្បីមើល ឬប៉ះពាល់សាកសព។ ក្តារមឈូសតំកល់សាកសពគួរត្រូវបានដាក់នៅទីតាំងឆ្ងាយសមរម្យពីអ្នកចូលរួមពិធីបុណ្យ ។
3. អ្នកទទួលភារកិច្ចលើកសពចូលក្នុងមឈូស និងលើកមឈូសទៅដាក់លើទីតាំងបូជា ឬទីបញ្ចុះសព ត្រូវពាក់ស្រោមដៃ។ នៅពេលរៀបចំរួចរាល់ ត្រូវដោះចេញនិងវេចខ្ចប់ស្រោមដៃដែលប្រើរួចយកទៅដុតចោល ឬចោលក្នុងធុងសម្រាមវេជ្ជសាស្ត្រ ហើយត្រូវលាងសម្អាតដៃជាមួយសាប៊ូនឹងទឹកស្អាតភ្លាម។
4. ក្រុមគ្រួសារ ញាតិមិត្ត មិនត្រូវប៉ះពាល់សពដោយផ្ទាល់ឡើយ។
5. ការតម្កល់ទុកសពនៅផ្ទះ ត្រូវធ្វើក្នុងរយៈពេលខ្លីបំផុត។ រដ្ឋបាលឃុំ-សង្កាត់ ត្រូវជួយសម្រួលផ្តល់លិខិតអនុញ្ញាតឱ្យបូជាឬបញ្ចុះសព ដល់ក្រុមគ្រួសារ ឬញាតិមិត្ត ឱ្យបានឆាប់រហ័ស។ ការសម្លាប់មេរោគលើសព ឬចាក់សារធាតុផ្សេងៗ ដូចជាហ្វ័រម៉ុលដើម្បីរក្សាទុកសព ពុំមានភាពចាំបាច់ទេ។
6. ការជួបជុំក្នុងពិធីបុណ្យសពនៅគេហដ្ឋាន ឬនៅទីតាំងបូជាឬបញ្ចុះសព ត្រូវមានចំនួនជាអតិបរមា ៣០នាក់ ក្នុងពេលជាមួយគ្នា និងត្រូវអនុវត្តវិធានការសុខាភិបាល ឱ្យបានខ្ជាប់ខ្ជួន ដោយកំណត់ចំនួនមនុស្សចូលរួមក្នុងកម្រិតអប្បបរមា ឬកំណត់ពេលវេលាអ្នកចូលរួមតាមរបៀបឆ្លាស់គ្នា ដើម្បីរក្សាគំលាតសុវត្ថិភាពបុគ្គល និងសង្គម។

## ៥.៣. ការដឹកជញ្ជូនសព និងការដង្ហែសព

សពត្រូវបានដឹកតាមរថយន្តដឹកសព ឬតាមមធ្យោបាយដឹកជញ្ជូនសមស្របផ្សេងៗទៀត យោងទៅតាមស្ថានការណ៍ជាក់ស្តែងរបស់មូលដ្ឋាន។

ក្រុមអ្នកដឹកជញ្ជូនសពត្រូវប្រុងប្រយ័ត្នជានិច្ចនៅពេលលើកទុកដាក់មឈូស ដោយត្រូវអនុវត្តតាមវិធានការណែនាំខាងក្រោម៖

| វិធានការត្រូវអនុវត្ត | |
|---|---|
| 1. លាងដៃឱ្យបានស្អាតជាមួយទឹកស្អាតនិងសាប៊ូឬទឹកសម្លាប់មេរោគ នៅមុននិងក្រោយពេលលើកទុកដាក់សព។ | ✓ |
| 2. ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាសពេទ្យធម្មតា (surgical mask) ស្រោមដៃ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីខ្លួនសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវបំពង់មិនជ្រាបទឹក បន្ថែមទៀត ។ | ✓ |
| 3. បន្ថយការលើកទុកដាក់សព ចុះឡើងឱ្យនៅតិចបំផុត | ✓ |
| 4. លាងសំអាតរថយន្ត ឬមធ្យោបាយដឹកជញ្ជូន ទាំងផ្នែកខាងក្នុង និងខាងក្រៅ ដោយប្រើទឹកសម្លាប់មេរោគ នៅក្រោយពេលដឹកជញ្ជូនរួចម្តងៗ ។ | ✓ |

## ៥.៤. ការបូជាសពឬបញ្ចុះសព

ក្រុមអ្នកមានភារកិច្ចលើកសាកសពដាក់ចូលក្នុងក្តារមឈូស និងលើកមឈូសដាក់លើឡបូជា ឬលើកមឈូសទៅបញ្ចុះ ត្រូវពាក់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជា ពាក់ម៉ាស និងស្រោមដៃ ជាដើម។ នៅពេលរៀបចំរួចរាល់ ត្រូវដោះឧបករណ៍ការពារខ្លួនដែលប្រើរួច វេចខ្ចប់ទុកដាក់ឱ្យបានត្រឹមត្រូវដើម្បីយកទៅដុតចោល ឬចោលក្នុងធុងសម្រាមវេជ្ជសាស្ត្រ ហើយលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាតភ្លាមៗ។

ក្រុមអ្នកបូជា ឬបញ្ចុះសព ត្រូវអនុវត្តវិធាន ដូចខាងក្រោម៖

1. លាងដៃឱ្យបានស្អាតជាមួយសាប៊ូ និងទឹកស្អាត ឬទឹកសម្លាប់មេរោគ នៅមុននិងក្រោយពេលលើកទុកដាក់សព។
2. ប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវ ដូចជាពាក់ម៉ាសពេទ្យ និងស្រោមដៃ។ បើគិតថាអាចប៉ះពាល់នឹងសារធាតុរាវ ឬទឹកចេញពីសាកសព ត្រូវពាក់របាំងមុខ ឬវ៉ែនតាការពារ និងអាវបំពង់មិនជ្រាបទឹកបន្ថែមទៀត។

## ៥.៥. ការគ្រប់គ្រង និងសម្អាតបរិស្ថាន នៅមន្ទីរពេទ្យ គេហដ្ឋាន ទីតាំងបូជាឬបញ្ចុះសព

ការលាងសម្អាត និងរក្សាបរិស្ថាននៅមន្ទីរពេទ្យ គេហដ្ឋាន ទីកន្លែងបូជាឬបញ្ចុះសពឱ្យបានត្រឹមត្រូវនិងមានអនាម័យល្អ គឺមានសារៈសំខាន់ណាស់។ ដូច្នេះ បុគ្គលិកសុខាភិបាល ក្រុមគ្រួសារ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរក្សាបរិស្ថានអនាម័យឱ្យបានល្អ ដោយអនុវត្តដូចតទៅ៖

1. បុគ្គលិកសម្អាតអនាម័យត្រូវប្រើប្រាស់ឧបករណ៍ការពារខ្លួន ដូចជា៖ ឧបករណ៍ការពារផ្លូវដង្ហើម និងភ្នែក ក្នុងពេលរៀបចំ និងប្រើប្រាស់សារធាតុសម្លាប់មេរោគ។
2. កន្លែង/បន្ទប់តម្កល់សពត្រូវធ្វើអនាម័យជានិច្ច។
3. ត្រូវលាងសម្អាតឧបករណ៍ដែលបានប្រើប្រាស់ក្នុងពេលពិនិត្យសពនីមួយៗ និងសម្លាប់មេរោគភ្លាមៗ បន្ទាប់ពីពិនិត្យរួច។
4. ត្រូវលាងសម្អាតផ្ទៃ និងបរិស្ថានក្នុងកន្លែង/បន្ទប់តម្កល់សព ជាមួយសាប៊ូ និងទឹក បន្ទាប់មកត្រូវលាងសម្អាតផ្ទៃនោះជាមួយសារធាតុអេតាណុល ៧០% យ៉ាងហោចឱ្យបាន ១នាទី ឬសារធាតុសម្លាប់មេរោគដែលមានកំហាប់សូដ្យូមអ៊ីប៉ូក្លរីតយ៉ាងតិច 0,១% (១000 ppm)។
5. ត្រូវគ្រប់គ្រង ទុកដាក់ និងចោលសំណល់ផ្សេង ឱ្យបានត្រឹមត្រូវស្របតាមនីតិវិធី និងគោលការណ៍ណែនាំស្តីពីការបង្ការ និងគ្រប់គ្រងការចម្លងរោគ របស់ក្រសួងសុខាភិបាល។